ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ០៧១/១៧ គ.ជ.ប.ជ

# របាយការណ៍បូកសរុបសកម្មភាព និងលទ្ធផលការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំត្រីមាសទី១ និងទិសដៅត្រីមាសទី២ ឆ្នាំ២០១៧

( គិតចាប់ពីថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៦ ដល់ថ្ងៃទី ២៥ ខែមីនាឆ្នាំ២០១៧ )

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជំរុញការសម្របសម្រួលជាមួយក្រុមការងារ អន្តរក្រសួង ស្ថាប័ន ព្រមទាំងរាជធានី-ខេត្ត ដើម្បីរកដំណោះស្រាយបញ្ហាប្រឈមនានា សុំឲ្យមានការស្រាវជ្រាវស៊ើបអង្កេតបទល្មើស និងសិក្សាពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ។

ស្ថានភាពពាក់ព័ន្ធអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយផ្អែកតាមរបាយការណ៍ដែលគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទទួលបានពីក្រសួង ស្ថាប័នពាក់ព័ន្ធ លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ក្រោមជាតិ បានរកឃើញបទល្មើសជាច្រើនករណី តាមទម្រង់ផ្សេងៗដូចជា ការធ្វើអាជីវកម្មផ្លូវភេទ សញ្ញាកម្ម ទេសន្តរប្រវេសន៍ស្វែងរកការងារ និងការស្វែងរកគូស្រករនៅក្រៅប្រទេស ។ ក្នុងចំណោមជនទេសន្តរប្រវេសន៍ ដែលកំពុងនៅក្រៅប្រទេស ទាំងស្របច្បាប់ និងមិនស្របច្បាប់ ត្រូវបានរងគ្រោះជាបន្តបន្ទាប់ ហើយបញ្ជូនមកកម្ពុជាវិញ មួយចំនួនបានត្រឡប់មកផ្ទះវិញដោយខ្លួនឯង និងខ្លះទៀតបាត់ដំណឹង ។ កត្តាទាំងអស់នេះ ជាបញ្ហាប្រឈម ដែលគណៈកម្មាធិការជាតិ គ.ជ.ប.ជ ត្រូវរួមសហការជាមួយបណ្ដាក្រសួង ស្ថាប័ន ដែលជាសមាជិក និងអង្គភាពដែលពាក់ព័ន្ធព្យាយាមបង្ការទប់ស្កាត់ និងដោះស្រាយបញ្ហារួមគ្នា ។ ថ្មីៗនេះ ក៏មានលេចចេញនូវបទល្មើសជួញដូរសរីរាង្គ ពេស្យាចារជាបុរស និងបទអន្តរការរវាងអ្នកសុំកូន និងស្ត្រីពពោះ(ពពោះជំនួស) ដើម្បីនាំយកទារកចេញទៅក្រៅប្រទេសថែមទៀត ដែលជាសញ្ញាណមួយថ្មីអាចពាក់ព័ន្ធនឹងបទល្មើស រត់ពន្ធ ឬជួញដូរទារកឆ្លងដែន ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ ដោះស្រាយ និងបង្ការទប់ស្កាត់ជាបន្ទាន់ ហើយត្រូវកសាងច្បាប់ដើម្បីគ្រប់គ្រងសកម្មភាពពពោះជំនួសឲ្យបានឆាប់ ។

អគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានទទួលរបាយការណ៍ក្នុងត្រីមាសទី១ពី ៖ ក្រុមការងារកិច្ចការយុត្តិធម៌(ក្រសួងយុត្តិធម៌), ក្រុមការងារការពារជនរងគ្រោះ (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) ក្រុមការងារអនុវត្តន៍ច្បាប់(អគ្គស្នងការដ្ឋាននគរបាលជាតិ) និងលេខាធិការដ្ឋានរាជធានី/ខេត្ត ចំនួន២១ (រាជធានីភ្នំពេញ, ខេត្តកោះកុង, ព្រះសីហនុ, កែប,តាកែវ, កណ្ដាល, ព្រៃវែង, ឧត្តរមានជ័យ, ប៉ៃលិន បន្ទាយមានជ័យ, បាត់ដំបង, ពោធិ៍សាត់, ព្រះវិហារ, សៀមរាប, កំពត, កំពង់ធំ, ត្បូងឃ្មុំ, ក្រចេះ, ស្ទឹងត្រែង រតនគិរី, កំពង់ចាម) (ខេត្តកំពង់ស្ពឺ, មណ្ឌលគិរី, កំពង់ឆ្នាំង និងខេត្តស្វាយរៀង ពុំមានរបាយការណ៍) ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ❖ ការអនុវត្តយុទ្ធសាស្ត្រទាំង៤

### ក. ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ

ក.១ ការងារច្បាប់ និងគោលនយោបាយជាតិ

ក.១.១-កិច្ចការច្បាប់

❖ ច្បាប់ និងលិខិតបទដ្ឋាន ដែលបានដាក់ឲ្យប្រើប្រាស់

- សន្ធិសញ្ញា ស្តីពី "បត្យាប័ន" រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសរុស្ស៊ី ចុះហត្ថលេខាថ្ងៃទី០១ ខែ០២ ឆ្នាំ២០១៧ (ក្រសួងយុត្តិធម៌)
- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចេញសេចក្តីសម្រេចលេខ០៣៧/១៧ ស.ស.រ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការតែងតាំងលោក **ពេញ វិបុល** អគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ ជាសមាជិកបន្ថែមក្រុមការងារកិច្ចការយុត្តិធម៌។

❖ **លិខិតបទដ្ឋានដែលកំពុងរៀបចំ**

- សេចក្តីព្រាងច្បាប់ ស្តីពី "**ការគ្រប់គ្រងការពពោះជំនួស**" (ក្រសួងកិច្ចការនារី)
- សេចក្តីព្រាងច្បាប់ ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**" (ក្រសួងយុត្តិធម៌)
- សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត "*សម្រាប់អនុវត្តលក្ខខណ្ឌការងារកម្មករការងារផ្ទះ*" (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)
- សេចក្តីព្រាងគោលនយោបាយស្តីពី "**កិច្ចការការពារកុមារតាមសាលារៀន**" (ក្រសួងអប់រំ យុវជន និងកីឡា)

### ខ.ការលើកកម្ពស់ការបង្ការទប់ស្កាត់

ក្នុងត្រីមាសទី១ ឆ្នាំ២០១៧នេះ នៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរ សមត្ថកិច្ច និងការធ្វើវេទិកាសាធារណៈ ផ្សព្វផ្សាយការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ ចំនួន៥.២១១ លើក មានអ្នកចូលរួមសរុបចំនួន៨៤០.២៣០នាក់ កើនឡើងចំនួន៣៨២.៨១៤នាក់ ស្មើនឹង ៨៣,៦៩% (ធៀបនឹងត្រីមាសទី១ឆ្នាំ២០១៦ មុនមានចំនួន៤៥៧.៤១៦នាក់) ក្នុងនោះស្ត្រីមានចំនួន២៩៨.៥៦៣នាក់។ (ឧបសម្ព័ន្ធទី១)

ខ.១-ការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាន

- ក្រុមការងារការិយាល័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ចូលរួមផ្សព្វផ្សាយក្នុងកម្មវិធីវិទ្យុ អំពីច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ចំនួន០៤លើក ។
- **ខេត្តកំពត** បានបញ្ចាំងខ្សែភាពយន្តរឿង "**ជើងមេឃនៅឯណា**"ចំនួន០២លើក អ្នកចូលរួមចំនួន ៥៦នាក់ (ស្រី២៣នាក់) ។

ខ.២-ការគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍

ខ.២.១-ការគ្រប់គ្រងបច្ចុប្បន្នភាពស្ថិតិចំណាកស្រុក

បច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស ប្រចាំខែនីមួយៗ បានពិនិត្យឃើញថា នៅតែបន្តកើតមានឡើង ជាក់ស្តែងក្នុងត្រីមាសទី១នេះ មានដូចតួលេខក្នុងតារាងខាងក្រោម៖

តារាងតាមដានបច្ចុប្បន្នភាពទិន្នន័យពលករខ្មែរចំណាកស្រុក ប្រចាំខែនីមួយៗ ក្នុងត្រីមាសទី១

| ប្រចាំខែ | សរុបរួម | | | | ស្របច្បាប់ | | | | មិនស្របច្បាប់ | | | | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | |
| | | | ប | ស | | | ប | ស | | | ប | ស | |
| មករា | ៣២០.៤៣៧ | ១៤៤.៩៣៩ | ២.៤៦៩ | ៣.៣០៤ | ១៧៩.៥៧២ | ៨៧.៤២០ | ៦៨៨ | ២៧៧ | ១៤០.៨៦៥ | ៥៧.៤២០ | ៧.៧៨១ | ៣.០២៧ | កើន ១.៩០៤ |
| កុម្ភៈ | ៣១៩.២៤៧ | ១៤០.២០១ | ៨.៩៦៥ | ៣.០៥៤ | ១៧៩.៨៣១ | ៨៣.៦៥៥ | ៥៨៩ | ២៤៤ | ១៣៩.៤១៦ | ៥៦.៥៤៦ | ៧.៣៧៦ | ២.៨១០ | ថយចុះ ១.១៩០ |
| មីនា | ៣២១.១៥៩ | ១៤០.៥០៧ | ៧.៨៩៤ | ៣.០១៤ | ១៨០.៧១២ | ៨៣.៨១៦ | ៥៨៩ | ២៤៤ | ១៤០.៤៤៧ | ៥៦.៦៩១ | ៧.៣០៥ | ២.៧៧០ | កើន ១.៩១២ |

## ខ.២.២-ការគ្រប់គ្រងភ្នាក់ងារជ្រើសរើសឯកជន បញ្ជូនពលករទៅធ្វើការនៅបរទេស

ក្រុមហ៊ុនឯកជន បានធ្វើការជ្រើសរើសបញ្ជូន និងគ្រប់គ្រង ពលករទៅធ្វើការដោយស្របច្បាប់នៅក្រៅប្រទេសចំនួន៤ សរុបចំនួន៤.៤០៨នាក់(ស្រីចំនួន១.៧៥០នាក់) ក្នុងនោះ៖

- តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(EPS)៖ ចំនួន៣២១នាក់ (ស្រី៣០នាក់)
- តាមរយៈភ្នាក់ងារជ្រើសរើសឯកជនមាន៖
  - ទៅប្រទេសថៃ ចំនួន៣.៧៩២នាក់ (ស្រី១.៥៧០នាក់)
  - ទៅប្រទេសជប៉ុន ចំនួន២០៩នាក់ (ស្រី១០៧នាក់)
  - ប្រទេសសិង្ហបុរី ចំនួន០៩នាក់ (ស្រី០៩នាក់)
- តាមរយៈភ្នាក់ងារជ្រើសរើសឯកជនចំនួន០៥លើក នៅក្នុងខេត្តប៉ៃលិន ដែលបានជ្រើសរើសពលករខ្មែរទៅធ្វើការនៅប្រទេសថៃ មានក្រុមហ៊ុនចំនួន០៤ ៖
  - ក្រុមហ៊ុន UNICORN MANPOWER CO.LTD បានបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃចំនួន១៥នាក់(ស្រី០៤នាក់) ។
  - ក្រុមហ៊ុន B.S.R.O BETS MANPOWER CO.LTD បានបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃចំនួន២០នាក់(ស្រី១០នាក់) ។
  - ក្រុមហ៊ុន SUPA WICH PATANAKIT CO.LTD បានបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃចំនួន១៤នាក់(ស្រី០២នាក់)លើកទី១ និងចំនួន១៤នាក់(ស្រី០៩នាក់)លើកទី២ ។
  - ក្រុមហ៊ុន CATM ASIA MANPOWER COOPERATION CO.LTD បានបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃចំនួន១៤នាក់(ស្រី០៩នាក់) ។

## ខ.៣-វិធានការគ្រប់គ្រងជំនាញ

### ខ.៣.១-ការងារបង្ការទប់ស្កាត់តាមវិធានការជំនាញ

- ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានធ្វើការបង្ការទប់ស្កាត់ និងអប់រំ ដល់ពលករដែលបម្រុងធ្វើចំណាកស្រុកទៅរកការងារធ្វើដោយមិនស្របច្បាប់ នៅប្រទេសថៃចំនួន០៤លើក មានពលករសរុបចំនួន៧៧នាក់ (ស្រី៣៣នាក់) ។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលរាជធានី/ខេត្ត បានធ្វើ៖
  - បច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញាកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់

អាជីវកម្ម ស្ត្រីក្នុងហាងម៉ាស្សា ខារ៉ាអូខេ ចំនួន៦០៧គោលដៅ មានមនុស្សចំនួន៣.៦៤១នាក់ (ស្រី២.៩៥៤នាក់) ។

  - បច្ចុប្បន្នភាពទិន្នន័យគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងអាជីកម្មផ្លូវភេទ ទូទាំងរាជធានី/ខេត្តចំនួន៦០គោលដៅ ក្នុង នោះអំពើជួញដូរមនុស្សចំនួន២៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន៣១គោលដៅ ។
  - មើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទចំនួន៥៨លើក ។

- **ខេត្តរតនគិរី** កម្លាំងនគរបាលវរៈការពារព្រំដែន (វរៈលេខ៦២៣ និង២០៣) ល្បាតឃ្លាំមើលគោលដៅសង្ស័យមានមុខសញ្ញាឆ្លងដែនខុសច្បាប់តាមព្រំដែនសរុបចំនួន២៦០លើក ក្នុងនោះម្ចាស់ការចំនួន៤៩លើក អង្កេតតាមព្រំដែនកម្ពុជា-ឡាវ១៦លើក និងព្រំដែនវៀតណាម៣៣លើក ។
- **ខេត្តបាត់ដំបង** កម្លាំងនគរបាលវរៈការពារព្រំដែនសេនាតូចលេខ៨១៧, ៨១៩, ៨២៣ និង៣១០ ល្បាតឃ្លាំមើលគោលដៅសង្ស័យ មានមុខសញ្ញាឆ្លងដែនខុសច្បាប់តាមព្រំដែន ចំនួន២៨១លើក ។

ខ.៣.២-ការបង្ការទប់ស្កាត់តាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរ និងជនបរទេស

របាយការណ៍ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនជាសេនាធិការបានសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស ដែលមកដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ បានចំនួន៤០១គូ និងបានសាកសួរសុខទុក្ខនារីខ្មែរដែលរៀបការរួចទៅនៅក្រៅប្រទេសដោយទំនាក់ទំនងតាមទូរស័ព្ទផ្ទាល់របស់សាមីខ្លួន បានចំនួន១២នាក់ (រស់នៅជាមួយគ្រួសារមានសេចក្តីសុខសប្បាយជាធម្មតា) ។

ខ.៣.៣-ការសម្ភាសពលករចាប់បញ្ជូនត្រឡប់តាមច្រកព្រំដែន(ផ្លូវគោក និងផ្លូវអាកាស)

- អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនជាសេនាធិការបានទទួលពលកររងគ្រោះចំនួន២៣នាក់ ក្នុងនោះមកពីប្រទេសម៉ាឡេស៊ី០៧នាក់ ឥណ្ឌូនេស៊ី១០នាក់ ឡាវ០២នាក់ និងប្រទេសចិន០៤នាក់ ។ តាមការសម្ភាសជនរងគ្រោះ បានធ្វើដំណើរទៅតាម៖
  - មេខ្យល់១០នាក់ (ម៉ាឡេស៊ី០៦នាក់ និងចិន០៤នាក់)
  - ដោយខ្លួនឯង១២នាក់ (ឥណ្ឌូនេស៊ី១០នាក់ និងឡាវ០២នាក់)
  - ក្រុមហ៊ុន០១នាក់ (ម៉ាឡេស៊ី) ។
- ក្រុមការងារការពារជនរងគ្រោះ នៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានស្រង់ឈ្មោះជនរងគ្រោះដែលបញ្ជូនមកពីក្រៅប្រទេស តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានចំនួន១០៧នាក់ (ស្រី៥៣នាក់, កុមារ១៤នាក់) ក្នុងនោះ៖

  - មកពីប្រទេសឥណ្ឌូនេស៊ីចំនួន ១៨នាក់
  - មកពីប្រទេសម៉ាឡេស៊ី ចំនួន ៣៧នាក់ (ស្រី២១នាក់)
  - មកពីប្រទេសវៀតណាមចំនួន ៣៨នាក់ (ស្រី២៤នាក់ កុមារ១៤នាក់)
  - មកពីប្រទេសចិន ចំនួន ១០នាក់ (ស្រី០៥នាក់)
  - មកពីប្រទេសថៃ ចំនួន ០៤នាក់ (ស្រី០៣នាក់)

## គ.ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

គ.១ ការងារអនុវត្តច្បាប់

គ.១.១-ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

ស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានខិតខំតាមដានស្រាវជ្រាវ

បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន៤១ករណី/១៧ករណី(បើប្រៀបធៀបនឹងត្រីមាសមុនកើនឡើង២៤ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូង បានចំនួន៤៦/២០នាក់ (អនីតិជន ០៥នាក់) ស្រីចំនួន១១នាក់ និងជនបរទេស០២នាក់ (ជប៉ុន និងអាមេរិក) សង្គ្រោះជនរងគ្រោះ បានចំនួន ៧២/៤៣នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំ២៨នាក់ អាយុពី១៥-១៧ឆ្នាំ០៥នាក់ និងអាយុ១៨ឆ្នាំឡើង៣៩នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន២៧នាក់ និង៤៥នាក់ទៀតប្រគល់ឲ្យគ្រួសារ) ។

➢ **អំពើជួញដូរមនុស្ស**

សរុប០៨ករណី/០៣ករណី ជនសង្ស័យចំនួន១១នាក់(ស្រី០៥នាក់) ជនរងគ្រោះចំនួន១៨នាក់ អាយុក្រោម១៥ឆ្នាំ០២នាក់ អាយុពី១៥-១៧ឆ្នាំ០២នាក់ និងអាយុ១៨ឆ្នាំឡើង០២នាក់ (ប្រគល់ឲ្យគ្រួសារចំនួន១៨នាក់)។

| | | |
|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០១ករណី | ជនសង្ស័យ ០១នាក់ |
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០៣ករណី | ជនសង្ស័យ ០៣នាក់ |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០១ករណី | ជនសង្ស័យ ០១នាក់ |
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០១ករណី | ជនសង្ស័យ ០៣នាក់ (សញ្ជាតិជប៉ុន០១នាក់) |
| -អំពើនាំឆ្លងដែន | ០១ករណី | ជនសង្ស័យ ០១នាក់ |
| -ការទិញពេស្យាចារកុមារ | ០១ករណី | ជនសង្ស័យ ០២នាក់ (សញ្ជាតិអាមេរិក០១នាក់) |

➢ **អំពើធ្វើអាជីវកម្មផ្លូវភេទ**

សរុប៣៣ករណី/១៤ករណី ជនសង្ស័យចំនួន៣៥នាក់ (ស្រី០៦នាក់) ជនរងគ្រោះចំនួន៥៤នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំ២៦នាក់ អាយុ១៥-១៧ឆ្នាំ០៣នាក់ អាយុ១៨ឆ្នាំឡើង២៥នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន២៧នាក់ និង២៧នាក់ ទៀតប្រគល់ឲ្យគ្រួសារ) ។

| | | |
|---|---|---|
| -ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ០១ករណី | ជនសង្ស័យ ០១នាក់ |
| -សញ្ជារកម្ម | ០៣ករណី | ជនសង្ស័យ ០៤នាក់ |
| -ស្ថានទម្ងន់ទោសនៃសញ្ជារកម្ម | ០១ករណី | ជនសង្ស័យ ០២នាក់ |
| -សញ្ជារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០២ករណី | ជនសង្ស័យ ០២នាក់ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១៩ករណី | ជនសង្ស័យ ១៩នាក់ (អនីតិជន០៤នាក់) |
| -អំពើអាសប្រាតនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៧ករណី | ជនសង្ស័យ ០៧នាក់ (អនីតិជន០១នាក់) |

គ.២ កិច្ចការយុត្តិធម៌

គ.២.១ លទ្ធផលចំណាត់ការផ្តន្ទាទោស (មិនមានរបាយការណ៍)

គ.២.១-ការរៀបចំបទដ្ឋានគតិយុត្តិ និងច្បាប់

○ **សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" កំពុងពិភាក្សាមានៈ**

- សន្ធិសញ្ញា ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ និងរដ្ឋាភិបាលបារាំង និងរដ្ឋាភិបាលរុស្ស៊ី ។

○ **សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"បត្យាប័ន" កំពុងពិភាក្សាមានៈ**

- សន្ធិសញ្ញា ស្តីពី"បត្យាប័ន" រវាងព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលឥណ្ឌា ។

○ សេចក្ដីព្រាងសន្ធិសញ្ញា ស្ដីពី"បញ្ជូនទណ្ឌិត" កំពុងពិភាក្សាមាន៖

- សេចក្ដីព្រាង កិច្ចព្រមព្រៀង ស្ដីពី"បញ្ជូនទណ្ឌិត" រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលអង់គ្លេស និង រដ្ឋាភិបាលប៉េរូ និងសាធារណរដ្ឋប្រជាមានិតឡាវ និង រដ្ឋាភិបាលរុស្ស៊ី ។

## ឃ.កិច្ចការពារជនរងគ្រោះ ព្រមទាំងសេវាគាំទ្រ

ឃ.១ ស្ថិតិពលករដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេស តាមច្រកព្រំដែន

ពលករទេសន្តរប្រវេសន៍ការងារបញ្ជូនត្រឡប់មកពីច្រកព្រំដែន សរុបចំនួន៣៣.១៦៣នាក់ (ស្រី១២.៣៤៥នាក់) កុមារចំនួន២.១៣០នាក់ (កុមារី៨៣៦នាក់) មានដូចតារាងលម្អិតខាងក្រោម៖

តារាងចំនួនពលករទេសន្តរប្រវេសន៍ ដែលបានបញ្ជូនមកតាមច្រក

| ល.រ | ខេត្ត | តាមច្រកទ្វារ | ចំនួនរួម | ស្រី | កុមារ | កុមារី | ពីប្រទេស | |
|---|---|---|---|---|---|---|---|---|
| | | | | | | | ថៃ | វៀតណាម |
| ១ | បន្ទាយមានជ័យ | អន្តរជាតិប៉ោយប៉ែត | ១៧.៦៧០ | ៦.១៦០ | ១.៧៣៦ | ៧៥៦ | ១៧.៦៧០ | |
| ២ | បាត់ដំបង | អន្តរជាតិដូង | ១៤.០៧៣ | ៥.៦៧២ | ១៩១ | | ១៤.០៧៣ | |
| | | ភ្នំដី(គីឡូម៉ែត្រ១៣) | ១.២៩៣ | ៤៤៨ | ១០៧ | ៥២ | ១.២៩៣ | |
| | | អូររំដួល | | | | | | |
| ៣ | ប៉ៃលិន | ដប់គគី | ១៦ | ៩ | | | ១៦ | |
| ៤ | ព្រះវិហារ | អានសេះ | ១៩ | | | | ១៩ | |
| | | ជាំ | ១៦ | | | | ១៦ | |
| ៥ | ស្វាយរៀង | អន្តរជាតិបាវិត | ៧៦ | ២៨ | ៤៨ | ១៤ | | ៧៦ |
| សរុប | | | ៣៣.១៦៣ | ១២.៣១៧ | ២.០៨២ | ៨២២ | ៣៣.០៨៧ | ៧៦ |

ចំណែកទេសន្តរប្រវេសន៍ចំនួន១.៤១៧នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនលើសពីរយៈពេល១ខែមុននឹងបញ្ជូនមកកម្ពុជា ហើយត្រូវអប់រំណែនាំឲ្យត្រឡប់ទៅលំនៅស្ថានវិញ ។

ឃ.២ ការទទួលជនសង្ស័យរងគ្រោះ

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖**

○ មន្ទីរ ស.អ.យ រាជធានីភ្នំពេញ ទទួលកុមាររងគ្រោះដោយអំពជួញដូរមនុស្ស, រំលោភបំពាន ផ្លូវភេទ និងកេងកម្លាំងពលកម្ម សរុបចំនួន០២នាក់ (ស្រី០១នាក់) បានបញ្ជូនទៅអង្គការ HAGA និងអង្គការសួនក្ដីសង្ឃឹមនៅកម្ពុជា ។

○ អង្គការរេណាសេដើរជាស្ត្រី-កម្ពុជា អង្គការក្ដីសង្ឃឹមនិងយុត្តិធម៌ អង្គការសង្គ្រោះជោគ វាសនាកម្ពុជា និងអង្គការបេសកកម្មទូទាំងពិភពលោក ទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជួញដូរផ្លូវភេទ ជួញដូរកម្លាំងពលកម្ម និងរំលោភបំពានផ្លូវភេទ សរុបចំនួន១៥៤នាក់ (ស្រី៣២នាក់ កុមារី១២២នាក់) បានបញ្ជូនទៅអង្គការដៃគូចំនួន០៥នាក់ ក្នុងនោះមាន អង្គការ ARM ខេត្តបាត់ដំបង០២នាក់ និងខេត្តសៀមរាប ARM ០៣នាក់ ។

ឃ.៣ កិច្ចការពារកុមារ

➢ **ការដកហូតកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប៖** Sitha

- ចុះអធិការកិច្ចពលកម្មកុមារនៅតាមឡូតដ្ឋ មានចំនួន២០ឡូតដ្ឋ ចំនួន០៣ស្រុក (ក្រឡាញ់ បន្ទាយស្រី និងអង្គរជំ និងបិទ០២កន្លែងនៅស្រុកបន្ទាយស្រី) សរុបមនុស្សចំនួន៥១៧នាក់ (ស្រី២៥៧នាក់) ក្នុងនោះកុមារចំនួន២៣៥នាក់ (កុមារី១១០នាក់) ។
- ចុះសម្រង់ស្ថិតិឡូតដ្ឋ សរុបមាន៤៦កន្លែង មានម្ចាស់អាជីវកម្ម៤៦នាក់ កំពង់ដំណើរការចំនួន៣៧កន្លែង បិទចំនួន០៣កន្លែង និងផ្អាកចំនួន០៥កន្លែង សរុបកម្មករ៧៨៧នាក់ (ស្រី៣៨០នាក់) ។

➢ **ការជួយកុមាររងគ្រោះដោយអំពើជួញដូរមនុស្ស**

- **អង្គការវេណាសេដើរជាមួយស្ត្រី-កម្ពុជា និងអង្គការក្តីសង្ឃឹម និងយុត្តិធម៌** បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងផ្លូវភេទចំនួន១០នាក់(ស្រី) ជួញដូរផ្លូវភេទ០៦នាក់ និងជួញដូរកម្លាំងពលកម្ម០៤នាក់ ។
- **មន្ទីរ ស.អ.យ ខេត្តក្រចេះ** បញ្ជូនកុមារីរងគ្រោះចំនួន០៥នាក់ ដែលធ្វើការនៅកន្លែងងាយរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន០៣នាក់ និងរងគ្រោះដោយអំពើរំលោភសេពសន្ថវៈចំនួន០២នាក់ ឲ្យទៅរស់នៅក្នុងមណ្ឌលអង្គការ ។
- **មន្ទីរ ស.អ.យ រាជធានីភ្នំពេញ** បានទទួលកុមាររងគ្រោះដោយអំពើជួញដូររំលោភបំពានផ្លូវភេទ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ចំនួន០១នាក់(ស្រី) ។
- **មន្ទីរ ស.អ.យ ខេត្តបាត់ដំបង៖**
  - សហការជាមួយអង្គការនៃក្តីសង្ឃឹមសម្រាប់យុត្តិធម៌ H&J ប៉ាន់ប្រមាណតម្រូវការគ្រួសារកុមាររងគ្រោះការជួញដូរកម្លាំងពលកម្មនៅប្រទេសថៃចំនួន០១នាក់ ឲ្យចូលរៀនជំនាញនៅមណ្ឌលអង្គការផ្ទាល់ ។
  - សហការជាមួយអង្គការនៃក្តីសង្ឃឹមសម្រាប់យុត្តិធម៌ H&J ស្វែងរកកុមាររងគ្រោះដោយការកេងប្រវ័ញ្ចផ្លូវភេទចំនួន០៣នាក់ ដើម្បីទទួលសេវាថែទាំ នៅអង្គការនៃក្តីសង្ឃឹម ។

ឃ.៤ ការគ្រប់គ្រងជនងាយរងគ្រោះក្នុងមណ្ឌល

- **រាជធានីភ្នំពេញ** បានទទួលជនអនាថាមិនស្ម័គ្រចិត្តសរុបចំនួន៤៤៧នាក់ (ស្រី៩៨នាក់) កុមារ៣៧នាក់ (កុមារី០៩នាក់) ដោយបញ្ជូនជនរងគ្រោះទាំងនេះ ទៅមន្ទីរ ស.អ.យ រាជធានីភ្នំពេញ ដើម្បីអប់រំ និងបណ្តុះបណ្តាលរយៈពេលខ្លី មុននឹងសមាហរណកម្មទៅសហគមន៍វិញ ។
- **ខេត្តពោធិ៍សាត់** មានមណ្ឌលថែទាំកុមារចំនួន១៥ ក្នុងនោះមានមណ្ឌលរដ្ឋ០១កន្លែង និងអង្គការ០៥កន្លែង និងអង្គការក្នុងសហគមន៍០៩កន្លែង ពិនិត្យលើការគាំពារ និងថែទាំបណ្តុះបណ្តាលជនរងគ្រោះ និងងាយរងគ្រោះ មានចំនួនសរុប៣៥៦នាក់ (ស្រី១៧១នាក់) ។
- **ខេត្តកំពង់ចាម** កុមារកំព្រា និងកុមារងាយរងគ្រោះ ការថែទាំនៅក្នុងមណ្ឌល សរុប០៦មណ្ឌល គ្រប់គ្រងដោយមណ្ឌលកុមារកំព្រារដ្ឋ០១មណ្ឌល និងអង្គការមិនមែនរដ្ឋាភិបាល០៥មណ្ឌល មានកុមារសរុប២២៩នាក់ (ស្រី៩៨នាក់) និងការថែទាំនៅតាមសហគមន៍ចំនួន០៧អង្គការ សរុប១,៣៨១នាក់ (ស្រី៤៩នាក់) ។
- **ខេត្តក្រចេះ**

- មន្ទីរសង្គមកិច្ចខេត្ត សហការជាមួយអង្គការកុមារកម្ពុជា SOSទទួលកុមារកំព្រាឲ្យមករស់នៅ សរុបចំនួន៩៨នាក់ (ស្រី៣៩នាក់) និងបានផ្តល់អាហារូបត្ថម្ភដល់កុមាររងគ្រោះ និងងាយរងគ្រោះ នៅសហគមន៍ចំនួន៣០០នាក់ (ស្រី១៥៧នាក់) Ftha

- ការិយាល័យសុខុមាលភាពកុមារ ចុះត្រួតពិនិត្យក្នុងមណ្ឌលអង្គការដំណឹងល្អទាំង៤ លើការ ថែទាំជំនួសចំពោះកុមារ ចំនួន២៩នាក់ (កុមារី១៤នាក់) ។

ឃ.៥ សេវាជួយជនរងគ្រោះដែលបានផ្តល់

- **មណ្ឌលសំចតប៉ោយប៉ែត** ទទួលជនរងគ្រោះចំនួន៣៦នាក់ (ស្រី១០នាក់) និងកុមារចំនួន២៦នាក់ (កុមារី១៤នាក់) ក្នុងចំណោមជនរងគ្រោះខាងលើរកឃើញថា៖ ជាករណីងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ជួញដូរកម្លាំងពលកម្ម កេងប្រវ័ញ្ចកម្លាំងពលកម្ម និងករណីជួញដូរផ្លូវភេទ ។ មណ្ឌលបានទំនាក់ទំនងបញ្ជូនជនរងគ្រោះទៅអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ, អង្គការដំណក់ទឹក និងផ្ទះសហគមន៍របស់អង្គការA21 ដើម្បីទទួលសេវាស្នាក់នៅ អប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សេវាផ្សេងៗ ក្នុងនោះបានផ្តល់សម្លៀកបំពាក់ សម្ភារប្រើប្រាស់ជាប្រចាំ ។

ឃ.៦ សមាហរណកម្មជនរងគ្រោះ

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖
  - **មន្ទីរ ស.អ.យ ខេត្តក្រចេះ** ចុះតាមដាន ត្រួតពិនិត្យអតិថិជន ដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញ ចំនួន៤៣នាក់ (រងគ្រោះដោយអំពើរំលោភបំពានផ្លូវភេទ១៤នាក់ និងរងគ្រោះដោយអំពើជួញដូរកម្លាំងពលកម្ម២៩នាក់) ។
  - អង្គការរេណាសេដើរជាមួយស្ត្រី-កម្ពុជា អង្គការក្តីសង្ឃឹម និងយុត្តិធម៌ និងអង្គការដោតវាសនាកម្ពុជា បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស, ជួញដូរផ្លូវភេទ និងជួញដូរកម្លាំងពលកម្ម ទៅសហគមន៍វិញសរុបចំនួន៤១នាក់ (ស្រី១៨នាក់) កុមារ២៣នាក់ (កុមារី២២នាក់) ។
- **ខេត្តកំពត** សមាហរណកម្មជនរងគ្រោះជាអនីតិជនចំនួន២២នាក់ (ស្រី១៣នាក់) ពីអង្គការពន្លឺព្រះអាទិត្យ មេត្រីភាពដើម្បីក្តីសង្ឃឹម អន្តរជាតិអាស៊ី និងអង្គការដៃគូរដទៃទៀត ។

## III. ការលើកកម្ពស់សមត្ថភាព

### ក.ក្នុងប្រទេស

ក.១-បណ្តុះបណ្តាល

ការងារបណ្តុះបណ្តាល ពង្រឹងសមត្ថភាព គ្រូបង្គោល មន្ត្រីអនុវត្តន៍ច្បាប់ និងប្រតិបត្តិករទេសចរណ៍ នៅតាមសណ្ឋាគារ និងប្រជាពលរដ្ឋ បាន១១វគ្គ និងមានសិក្ខាកាមចូលរួមចំនួន៤៦៤នាក់ (ស្រី១៣៧នាក់) ស្តីពីជំនាញពាក់ព័ន្ធនឹងច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងកិច្ចការពារជនរងគ្រោះ ដូចមានខាងក្រោម៖

- **មន្ទីរសង្គមកិច្ចខេត្តក្រចេះ** បើកវគ្គបណ្តុះបណ្តាលចំនួន០៣វគ្គ ស្តីពីកិច្ចការការពារ ទប់ស្កាត់ការជួញដូរមនុស្ស ការរំលោភបំពាន និងការធ្វើអាជីវកម្មផ្លូវភេទ ដល់ប្រជាពលរដ្ឋសរុបចំនួន១០៣នាក់ (ស្រី៥៦នាក់) ។
- **មន្ទីរកិច្ចការនារីខេត្តឧត្តរមានជ័យ** បើកវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស អ្នកចូលរួមចំនួន៤៥នាក់ (ស្រី៣៩នាក់) ។
- **ខេត្តត្បូងឃ្មុំ** ស្រុកតំបែរ និងស្រុកពញាក្រែក សហការជាមួយអង្គការការស៊ីស្វា បើកវគ្គបណ្តុះបណ្តាលចំនួន០២វគ្គ ស្តីពីតួនាទីនគរបាលយុត្តិធម៌ និងសិទ្ធិកុមារពាក់ព័ន្ធទៅនឹងច្បាប់ជូនដល់ប៉ុស្តិ៍នគរបាល ក្រុមប្រឹក្សាឃុំ និងអ្នកទទួលបន្ទុកកិច្ចការនារីឃុំ អ្នកចូលរួមចំនួន៤៧នាក់ (ស្រី១៥នាក់) ។
- **ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តព្រៃវែង** សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បើកវគ្គបណ្តុះបណ្តាល ស្តីពីការងារទាក់ទងនឹងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន២៨នាក់ (ស្រី០៥នាក់) ។

- **មន្ទីរទេសចរណ៍ខេត្តសៀមរាប** បើកវគ្គបណ្តុះបណ្តាល ស្តីពីបដិសណ្ឋារកិច្ចល្អជូនដល់បុគ្គលិកបម្រើការងារនៅមណ្ឌលកម្សាន្ត មនុស្សពេញវ័យនៅមណ្ឌលកម្សាន្តនាងពួន និងមណ្ឌលកម្សាន្ត New Star សិក្ខាកាមចូលរួមចំនួន១២៥នាក់ ។
- **លេខាធិការដ្ឋានខេត្តព្រះសីហនុ** សហការជាមួយមន្ត្រីទេសចរណ៍ បើកវគ្គបណ្តុះបណ្តាលចំនួន០២វគ្គ ជំនាញបដិសណ្ឋារកិច្ច និងសេវាកម្មទេសចរណ៍ ដោយបញ្ជ្រាបបញ្ហាយេនឌ័រ និងការធ្វើអាជីវកម្មទេសចរណ៍ផ្លូវភេទ និងការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ សិក្ខាកាមចូលរួមចំនួន៧១នាក់ (ស្រី២២នាក់) ។
- **អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** ជាសេនាធិការបានសហការជាមួយអង្គការ UNODC បើកវគ្គបណ្តុះបណ្តាល ស្តីពីការស៊ើបអង្កេតបទល្មើសតាមប្រព័ន្ធ បច្ចេកវិទ្យា សិក្ខាកាមចូលរួមចំនួន៤៥នាក់ មកពី(ប្រទេសឥណ្ឌូនេស៊ី០១នាក់ ហ្វីលីពីន០១នាក់, ថៃ០១នាក់, វៀតណាម០១នាក់ និងប្រទេសម៉ាឡេស៊ី០១នាក់) នៅសណ្ឋាគារ Green Palace Hotel ភ្នំពេញ ។

ក.២-សិក្ខាសាលា

- **លេខាធិការដ្ឋានខេត្តបាត់ដំបង** សហការជាមួយអភិបាលស្រុក អធិការដ្ឋាននគរបាលស្រុក ការិយាល័យពាក់ព័ន្ធ មេឃុំ និងភ្នាក់ងារជ្រើសរើសឯកជន រៀបចំសិក្ខាសាលា ស្តីពីការបញ្ជូនពលករទៅធ្វើការនៅបរទេស ដែលមានស្រុកគោលដៅទាំង៥ ចូលរួម ។

ក.៣-សម្របសម្រួលកិច្ចប្រជុំ

ការងារដឹកនាំសម្របសម្រួលសរុបបានចំនួន១៣៤លើក៖ ដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន៦៦លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាចំនួន១២លើក និងដោយលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន៥៦លើក។ (**ឧបសម្ព័ន្ធទី២**)

## ខ.ក្រៅប្រទេស

ខ.១ ចូលរួមប្រជុំ

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)៖
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដឹកនាំគណៈប្រតិភូកម្ពុជា១០រូប ដើម្បីចូលរួមកិច្ចប្រជុំលើកទី១ ឆ្នាំ២០១៧ ស្តីពីការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស រវាងរដ្ឋាភិបាលចិន-កម្ពុជា នៅទីក្រុងហ្វងសាន ខេត្តអានហួយ សាធារណរដ្ឋប្រជាមានិតចិន ។
  - បញ្ជូនប្រធានក្រុមកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីចូលរួមក្នុងវេទិកា Interpol ស្តីពីការរួមគ្នាដើម្បីសន្តិសុខ និងការទទួលខុសត្រូវសម្រាប់សន្តិភាពពិភពលោក នៅទីក្រុង Abu Dhabi ប្រទេសអារ៉ាប់រួម ។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
  - ចូលរួមប្រជុំពិគ្រោះយោបល់ទ្វេភាគី រវាង រាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃឡង់ដ៍ លើកទី១៤ ស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស (នៅខេត្តឈៀងម៉ៃ ប្រទេសថៃឡង់ដ៍)។
  - ចូលរួមកិច្ចប្រជុំលើកទី១ ឆ្នាំ២០១៧ ស្តីពីការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស រវាងរដ្ឋាភិបាលចិន-កម្ពុជា នៅទីក្រុងហ្វងសាន ខេត្តអានហួយ សាធារណរដ្ឋប្រជាមានិតចិន ។

- **ខេត្តព្រះវិហារ** ចូលរួមប្រជុំជាមួយប្រទេសឡាវ ស្តីពីកិច្ចសហប្រតិបត្តិការ ការពារសន្តិសុខ តាមបណ្តោយព្រំដែន និងបញ្ហាពលករធ្វើចំណាកស្រុកដោយប្រថុយប្រថាន ដើម្បីស្វែងរកការងារធ្វើនៅក្រៅប្រទេស និងពាក់ព័ន្ធអំពើជួញដូរមនុស្សឆ្លងដែនខុសច្បាប់ ។

ខ.២-សិក្ខាសាលា

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ចូលរួមសិក្ខាសាលាថ្នាក់តំបន់មេគង្គលើកទី៥៧ ស្តីពីការកំណត់អត្តសញ្ញាណ និងផ្តល់សេវាជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស (នៅទីក្រុងបាងកក ប្រទេសថៃឡង់ដ៏)។
- **អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** ជាសេនាធិការបានបញ្ជូននគរបាលជាន់ខ្ពស់០៣រូប ចូលរួមសិក្ខាសាលា៖
    - ស្តីពីថ្នាក់អនុតំបន់មេគង្គលើកទី៧ ដើម្បីស្រាវជ្រាវរកអត្តសញ្ញាណជនជួញដូរមនុស្ស និងផ្តល់សេវាជួយជនរងគ្រោះ និងចែករំលែកបទពិសោធន៍ឲ្យគ្នា រវាងប្រទេសក្នុងអនុតំបន់មេគង្គ (នៅប្រទេសថៃ) ។
    - ស្តីពីកិច្ចសហការអនុវត្តច្បាប់ក្នុងការទប់ស្កាត់ ការជួញដូរមនស្ស និងរត់ពន្ធទេសន្តប្រវេសន៍ក្នុងតំបន់អាស៊ីអាគ្នេយ៍ (ប្រទេសម៉ាឡេស៊ី) ។

## IV. សន្និដ្ឋាន និងវាយតម្លៃ

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើងតាមរយៈ ៖

- របាយការណ៍ប្រចាំខែ ពីបណ្តាក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន គណៈកម្មាធិការរាជធានី/ខេត្តដៃគូជាតិ អន្តរជាតិ និងអង្គភាពពាក់ព័ន្ធ
- រកដំណោះស្រាយបញ្ហាពលករដែលថៃចាប់បញ្ជូនតាមច្រកដូង ខេត្តបាត់ដំបង មានការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ
- តាមដានការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្របដល់ជនរងគ្រោះ ក្រោយការបណ្តុះបណ្តាលរួចមាន៖ (ខេត្តកណ្តាល, បន្ទាយមានជ័យ, សៀមរាប, រាជធានីភ្នំពេញ និងខេត្តកំពង់ចាម)
- ការចុះតាមដានការអនុវត្តការងារមន្ត្រីនគរបាលយុត្តិធម៌របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ក្នុងពេលប្រតិបត្តិការ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចការងារជាលទ្ធផលជោគជ័យគួរកត់សម្គាល់៖

១. បានរៀបចំក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នឹងបន្តសកម្មភាពដឹកនាំជាយុទ្ធសាស្ត្ររបស់ក្រុមការងារទាំង៦ និងថ្នាក់ក្រោមជាតិ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការរួមគ្នា លើកវិធានការ ការងារបង្ការទប់ស្កាត់និងបង្ក្រាបបទល្មើសជួញដូរមនុស្ស ។

២.របៀបរបបការងារ និងទំនាក់ទំនងសហប្រតិបត្តិការរវាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ត្រូវបានពង្រឹងនិងពង្រីកយ៉ាងទូលំទូលាយ ឆ្ពោះទៅកាន់គោលដៅរួមតែមួយ។ ~~ftha

៣. កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារអនុវត្តន៍ច្បាប់ ដែលបានអនុវត្តទៅតាមតួនាទី និងភារកិច្ចដែលបានដាក់ចុះសម្រេចបាននូវលទ្ធផលគួរឲ្យកត់សម្គាល់។
៤. បានខិតខំស្វែងរកការគាំទ្រ និងកិច្ចសហការពីអង្គការជាតិ អន្តរជាតិ ជាដៃគូនានា សំដៅអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែមានប្រសិទ្ធភាព។

## ខ. ចំណុចខ្វះខាត និងបញ្ហាប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈមនឹងសេសសល់មួយចំនួនដូចជា ៖

- ការផ្តល់របាយការណ៍ ពីក្រុមការងារ និងរាជធានី/ខេត្ត មួយចំនួនមកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីធ្វើការបូកសរុបមានការយឺតយ៉ាវ ។
- សមត្ថភាព និងធនធានមួយចំនួនដែលចាំបាច់សម្រាប់ការអនុវត្តច្បាប់នៅមានកម្រិត ដែលទាមទារឲ្យពង្រឹងបន្ថែម ទើបអាចឆ្លើយតបទៅនឹងសភាពការណ៍នៃបទល្មើស ។
- កិច្ចសហការពីអ្នកពាក់ព័ន្ធ ក្នុងនោះមានជនរងគ្រោះ នៅមិនទាន់ឆ្លើយតបទាន់សភាពការណ៍ ។
- ការទទួលព័ត៌មាន និងការអប់រំ ផ្សព្វផ្សាយ អំពីកលល្បិចរបស់ជនខិលខូចនៅមិនទាន់បានទូលំទូលាយនៅឡើយសម្រាប់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋ ដែលរស់នៅតំបន់ជនបទដាច់ស្រយាលដែលជាចំណុចចន្លោះប្រហោងមួយសម្រាប់ពួកឈ្មួញទុច្ចរិតងាយធ្វើការអូសទាញ បោកបញ្ឆោតទាំង បុរស ស្ត្រី និងកុមារ ឲ្យជឿជាក់ និងធ្វើទេសន្តរប្រវេសន៍ដោយខុសច្បាប់ ។
- ប្រជាពលរដ្ឋមានជីវភាពរស់នៅខ្វះខាត ហើយចំណេះដឹង និងការអប់រំរបស់ពួកគាត់នៅមានកម្រិតដូច្នេះទើបធ្វើឲ្យពួកគាត់ធ្វើការសម្រេចចិត្តរួសរាន់ទៅតាមការអូសទាញរបស់ឈ្មួញទុច្ចរិត។
- រចនាសម្ព័ន្ធ នៃគណៈកម្មាធិការរាជធានី/ខេត្ត និងលេខាធិការដ្ឋានថ្នាក់ក្រោមជាតិមួយចំនួន មិនទាន់បានរៀបចំត្រឹមត្រូវច្បាស់លាស់ ក្នុងការធ្វើការតាមដានការងារជាប្រចាំ និងពុំទាន់មានថវិកាគ្រប់គ្រាន់សម្រាប់ចំណាយលើការងារថ្នាក់ក្រោមជាតិ ។

## V. ទិសដៅត្រីមាសទី២ ឆ្នាំ២០១៧

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួម បែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព ។
២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ដកហូតសរីរាង្គ រត់ពន្ធទារក កុមារឆ្លងដែន ការជួញដូរពលកម្មក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។ មកលើប្រជាជនកម្ពុជា ។
៣. រៀបចំសកម្មភាពសម្រាប់ការអនុវត្តផែនការសកម្មភាពជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ពាក់កណ្តាល អាណត្តិទី២ ៖ ២០១៧-២០១៨) ។
៤. ត្រៀមចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា-ឥណ្ឌា និងជាមួយប្រទេសពាក់ព័ន្ធដទៃទៀត ។
៥. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៦. គាំទ្រ និងពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី/ខេត្ត។

៧. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀតឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៨. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជាក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៩. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

១០. ជំរុញតាមដាន ត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

១១. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ)។

១២. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ ។

១៣. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល ។៚

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០១៧

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជ.ប៊ុនអេង

**ចម្លងជូន**

-ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តន៍

# ឧបសម្ព័ន្ធទី១

## ការខារផ្សព្វផ្សាយ

| ល.រ | អង្គភាព | សកម្មភាព | អ្នកពាក់ព័ន្ធ | លើក | ចំនួនមនុស្ស | ស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី/ខេត ផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុត្ថិភាព អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស ។ | ស្នងការដ្ឋាននគរបាលខេត្ត | 831 លើក | 264,124 នាក់ | 33,783 នាក់ |
| 2 | កណ្តាល | ផ្សព្វផ្សាយអំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការធ្វើចំណាកស្រុក ដល់ប្រជាពលរដ្ឋ ។ | ក្រុមការងារថ្នាក់ស្រុក | 145 លើក | 13,779 នាក់ | 7,914 នាក់ |
